**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ ១៧១៤០ អពដ

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារពេលបង់ពន្ធលើអចលនទ្រព្យ សម្រាប់ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១៧

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនម្ចាស់អចលនទ្រព្យទាំងអស់ ដែលមានអចលនទ្រព្យស្ថិតក្នុងភូមិសាស្ត្រត្រូវជាប់ពន្ធលើអចលនទ្រព្យ នៃរាជធានី-ខេត្ត ទូទាំងព្រះរាជាណាចក្រកម្ពុជា មេត្តាជ្រាបថា អគ្គនាយកដ្ឋានពន្ធដារពិនិត្យឃើញថា រហូតមកទល់ពេលនេះ មានម្ចាស់អចលនទ្រព្យជាច្រើនបានមកប្រកាសបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១៧ ហើយក៏នៅមានម្ចាស់អចលនទ្រព្យមួយចំនួនទៀត នៅមិនទាន់បានបំពេញកាតព្វកិច្ចបង់ពន្ធប្រភេទនេះនៅឡើយទេ។

ដើម្បីបង្កលក្ខណៈងាយស្រួល និងផ្តល់លទ្ធភាពជូនម្ចាស់អចលនទ្រព្យដែលមិនទាន់បានមកប្រកាសបង់ពន្ធ មានពេលវេលាគ្រប់គ្រាន់ក្នុងការមកប្រកាសបង់ពន្ធនេះ អគ្គនាយកដ្ឋានពន្ធដារសម្រេចពន្យារពេលនៃការប្រកាសបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ**២០១៧** នេះ រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ**២០១៧**។ ម្ចាស់អចលនទ្រព្យទាំងឡាយ ដែលមិនមកប្រកាសបង់ពន្ធក្នុងអំឡុងពេល ឬក្រោយការពន្យារពេលខាងលើនេះ នឹងត្រូវទទួលរងនូវទោសទណ្ឌ ស្របតាមច្បាប់ស្តីពីសារពើពន្ធ ជាធរមាន។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថា ក្នុងអំឡុងពេលនៃការពន្យារការបង់ពន្ធប្រភេទនេះ ម្ចាស់អចលនទ្រព្យទាំងអស់នឹងរួសរាន់មកប្រកាសបង់ពន្ធបានទាន់ពេលវេលា និងបានគ្រប់ៗគ្នា តាមការកំណត់ជាក់ជាមិនខាន។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**